FROM : ISAR NO. : 85523366904 NOV. 13 2003

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

អាហារូបករណ៍ និង របបឧបត្ថម្ភជីវភាពអន្តេវាសិក

*******

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**មាត្រា ១ :** អាហារូបករណ៍ប្រចាំខែរបស់សិស្ស និង និស្សិត ដែលបានបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សាលាឯកទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់តាមកំរិតដូចមានខាងក្រោម ៖

- ក្រោយឧត្តមសិក្សា : ១២. ០០០៛
- ឧត្តមសិក្សា : ១០. ០០០៛
- មធ្យមសិក្សាឯកទេស : ៩. ០០០៛
- បឋមសិក្សាឯកទេស : ៨. ០០០៛

របបឧបត្ថម្ភអាហារូបករណ៍នេះ ត្រូវអនុវត្តចាប់តាំងពី ខែមីនា ឆ្នាំ១៩៩៧ នេះតទៅ ។

**មាត្រា ២ :** ការផ្តល់អាហារូបករណ៍ប្រចាំខែត្រូវអនុវត្តតែក្នុងរយៈពេលកំពុងសិក្សា។ ពេលឈប់សំរាកក្នុងឱកាសមហាវិស្សមកាល និង ពេលបញ្ចប់ការសិក្សា សិស្ស និស្សិតមិនត្រូវបានទទួលប្រាក់ អាហារូបករណ៍ទៀយ។

ក្នុងករណីសិស្ស និស្សិតរៀនត្រួតថ្នាក់ រដ្ឋនឹងផ្តាច់អាហារូបករណ៍វិញលើកលែងតែសិស្ស និស្សិតដែលស្ម័គ្រចិត្តធ្វើគ្រូ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សានោះ ។

**មាត្រា៣ :** ចំនួនសិស្ស និស្សិត ដែលត្រូវទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ ៖

ក - នៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស :

- កំរិតក្រោយឧត្តមសិក្សា : ៥០ ភាគរយ
- កំរិតឧត្តមសិក្សា : ១០ ភាគរយ
- កំរិតមធ្យមសិក្សាឯកទេស : ៣០ ភាគរយ
- កំរិតបឋមសិក្សាឯកទេស : ៣៥ ភាគរយ

- និស្សិតកំរិតក្រោយឧត្តមសិក្សា និង ឧត្តមសិក្សា ការកំណត់អត្រាអាហារូបករណ៍ ៥០ភាគរយ និង ១០ភាគរយ នឹងត្រូវអនុវត្តពីឆ្នាំសិក្សា ១៩៩៧ - ៩៨ តទៅ ចំពោះនិស្សិតដែលទើបប្រលងជាប់ថ្មី។
- និស្សិតក្រោយឧត្តមសិក្សា និង ឧត្តមសិក្សា ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា ត្រូវបានទទួលអាហារូបករណ៍ប្រចាំខែ តាមកំរិតដូច~~ក្នុងមាត្រា ១ តាមអត្រាភាគរយខាងលើ~~ គឺ ១០០ភាគរយ និង ៣០ភាគរយ រហូតដល់បញ្ចប់ការសិក្សារបស់ខ្លួន ។
- សិស្ស និស្សិត មធ្យមសិក្សាឯកទេស និង បឋមសិក្សាឯកទេស ត្រូវអនុវត្តតាមស្មារតីអនុក្រឹត្យថ្មីនេះ។

ខ ផ្នែកបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កំរិតសិក្សា ផ្នែកកីឡា និង សៀក ត្រូវបានទទួលអាហារូបករណ៍មួយរយភាគរយ ។

**មាត្រា ៤ :** - អាទិភាពក្នុងការផ្តល់អាហារូបករណ៍

ការផ្តល់អាហារូបករណ៍ ត្រូវអនុវត្តតាមគោលការណ៍អាទិភាពដូចខាងក្រោម ៖

១- សិស្ស និស្សិត គោរពវិន័យបានល្អ និង រៀនពូកែ

២- កូនកំព្រាឪពុក ម្តាយ និង មានជីវភាពរស់នៅជួបការលំបាកខ្លាំង

៣- កូនជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល

៤- កូនកសិករ ក្រ និង កូនមន្ត្រីរាជការដែលឪពុក ម្តាយមានជីវភាពរស់នៅជួបការលំបាក។

- ក្នុងអាទិភាពទាំង៤ ខាងលើ នារីភេទត្រូវបានយកចិត្តទុកដាក់មុនគេ ។

**មាត្រា ៥ :** ការកំណត់ឈ្មោះ សិស្ស និស្សិត ដែលត្រូវបានទទួលអាហារូបករណ៍ និង ការពិនិត្យវាយតំលៃផ្តល់អាទិភាពដូចក្នុងមាត្រា៣ និង មាត្រា៤ ខាងលើត្រូវធ្វើមួយឆ្នាំម្តងដោយក្រុមប្រឹក្សាវិន័យរបស់សាលា ។

**មាត្រា ៦ :** ចំពោះមន្ត្រីរាជការគ្រប់ប្រភេទ ដែលស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតអោយទៅចូលរួមសិក្ខាសាលា ធ្វើក្រឹតការ សុក្រឹត្យការ ឬ បំប៉នមុខជំនាញផ្សេងៗរយៈពេលពីមួយ " ០១ " ថ្ងៃដល់ " ១០ " ថ្ងៃ ត្រូវទទួលប្រាក់ស្នាក់នៅ និង បេសកម្មតាមច្បាប់រដ្ឋ ។ រយៈពេលសិក្សាចាប់ពីជាង១ខែ " ០១ " ខែរហូតដល់មិនលើសពី " ១២ " ខែ ត្រូវទទួលប្រាក់ឧបត្ថម្ភអន្តេវាសិកចំនួន " ២.០០០៛ " ក្នុងមួយថ្ងៃ ។ ចំពោះសិក្ខាកាមដែលមានទីលំនៅផ្ទាល់នៅជិត អាចទៅមកស្នាក់នៅផ្ទះរបស់ខ្លួនបានត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន " ១.០០០៛ " ក្នុងមួយថ្ងៃ ។

**មាត្រា ៧ :** សិស្សជនជាតិភាគតិច និង កូនអ្នកក្រីក្រដែលមានជីវភាពក្រលំបាកខ្លាំង នៅតំបន់ដាច់ស្រយាលដែលរដ្ឋបានកំណត់ ហើយដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាននៃអនុវិទ្យាល័យ វិទ្យាល័យ ឬ ទីប្រជុំជនស្រុក ឃុំ ដែលមានអន្តេវាសិកដ្ឋានត្រូវបានទទួលប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃម្នាក់ៗចំនួនមួយពាន់ ១.០០០៛ រៀល និង របបឧបត្ថម្ភសំភារៈផ្សេងៗ និង សំភារៈសិក្សាប្រចាំឆ្នាំក្នុងម្នាក់ៗចំនួន "ប្រាំបីម៉ឺនបីរយរៀល" ៨០.៣០០៛ រៀល ។

មាត្រា ៨ ៖ ក្រសួងអប់រំយុវជន និង កីឡា មានភារកិច្ចណែនាំអនុវត្តអនុក្រឹត្យនេះ ។

អនុក្រឹត្យ សេចក្តីសំរេច និង បទបញ្ញាទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ គ្រឹះស្ថាន ឧត្តមសិក្សា និង សិក្សាឯកទេសទាំងអស់ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ... ចាប់ពីថ្ងៃ ... ព្រះមហាក្សត្រ និង ចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

តុល ឡោះ

កន្លែងទទួល៖
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- គ្រប់ក្រសួង ស្ថាប័ន
- កាលប្បវត្តិ - ឯកសារ

ចម្លងចេញពីច្បាប់ដើមត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ... ខែ... ឆ្នាំ១៩៩...
...រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ប្រធានខុទ្ទ...